**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់កម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទ និងលេខទូរគមនាគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ ទៅតាមក្រសួង ខេត្តក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណង និង គោលដៅកំណត់ការកែសម្រួលកម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទ និងលេខទូរគមនាគមន៍ ដើម្បីប្រសិទ្ធភាពក្នុងការគ្រប់គ្រង និង ការទប់ស្កាត់ការប្រើប្រាស់ដោយខ្ជះខ្ជាយនូវធនធានកម្មសិទ្ធិរបស់រដ្ឋ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះប្រតិបត្តិការទូរគមនាគមន៍គ្រប់ប្រភេទដែលប្រើប្រាស់លេខទូរស័ព្ទ និង លេខទូរគមនាគមន៍ ជាធនធានកម្មសិទ្ធិរបស់រដ្ឋសម្រាប់ផ្ដល់សេវាទូរគមនាគមន៍គ្រប់ប្រភេទជូនសាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

និយមន័យនៃពាក្យបច្ចេកទេសក្នុងអនុក្រឹត្យនេះមានដូចតទៅ៖

- **ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** (ក.ប.ទ.) សំដៅអាណាព្យាបាលបច្ចេកទេសរបស់និយ័តករទូរគមនាគមន៍កម្ពុជា ។
- **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (ក.ស.ហ.វ.) សំដៅអាណាព្យាបាលហិរញ្ញវត្ថុរបស់និយ័តករទូរគមនាគមន៍កម្ពុជា ។
- និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) សំដៅនីតិបុគ្គលនៃនីតិសាធារណៈ ដែលបានទទួលសិទ្ធិពីរាជរដ្ឋាភិបាល មានមុខងារនិងភារកិច្ច ដោយស្វ័យភាពខាងផ្នែករដ្ឋបាល និង និយ័តកម្ម

ព្រមទាំងឯកពជ្យពីប្រតិបត្តិករទូរគមនាគមន៍ និង បុគ្គលពាក់ព័ន្ធនឹងវិស័យ ទូរគមនាគមន៍ស្របតាមមាត្រា ១០ នៃច្បាប់ស្តីពីទូរគមនាគមន៍។

- **ប្រតិបត្តិករទូរគមនាគមន៍** (Telecommunication Operator) សំដៅដល់នីតិបុគ្គលដែលទទួលអាជ្ញាបណ្ណធ្វើប្រតិបត្តិការទូរគមនាគមន៍ទាំងអស់ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។
- **លេខទូរគមនាគមន៍** (Telecommunication Number) សំដៅដល់លេខ លេខកូដ និងសញ្ញាសម្គាល់ពិសេសទូរគមនាគមន៍។
- **លេខទូរស័ព្ទ** (Telephone Number) សំដៅដល់លេខទូរស័ព្ទចល័ត ឬអចល័ត ដែលបានផ្តល់ជូនទៅប្រតិបត្តិករទូរគមនាគមន៍ ដោយ ន.ទ.ក. សម្រាប់ផ្តល់ជូនអ្នកប្រើប្រាស់បណ្តាញ និងសេវាទូរស័ព្ទចល័ត ឬអចល័ត។
- **លេខទូរស័ព្ទកំពុងដំណើរការ** (Active Number) សំដៅដល់លេខទូរស័ព្ទទាំងឡាយណាដែលបានផ្តល់ជូនអ្នកប្រើប្រាស់ ដោយប្រតិបត្តិករទូរគមនាគមន៍ឱ្យដំណើរការ និង មានប្រតិបត្តិការយ៉ាងហោចណាស់ម្តងក្នុងអំឡុងរយៈពេល ៣ ខែចុងក្រោយ លើការប្រើប្រាស់សេវាណាមួយដូចជា ហៅចេញ ហៅចូល ឬ ផ្ញើសារខ្លី ឬ ពហុសារ។
- **លេខទូរស័ព្ទពុំទាន់ដំណើរការ** (Inactive Number) សំដៅដល់លេខទូរស័ព្ទដែលជាផលដកនៃចំនួនលេខទូរស័ព្ទសរុប ដែលទទួលបានសិទ្ធិអនុញ្ញាតកាន់កាប់ ពីនិយ័តករទូរគមនាគមន៍កម្ពុជា និងលេខទូរស័ព្ទកំពុងប្រើប្រាស់។
- **ប្លុកលេខ** (Block Number) សំដៅដល់ចំនួនលេខទូរស័ព្ទអចល័ត ដែលមាន ១.០០០ (មួយពាន់) លេខបានកំណត់ជាក់លាក់ក្នុងមួយប្លុក។
- **លេខកូដខ្លីសម្រាប់សេវាគ្រាអាសន្ន** (Short Code Number for Emergency Services) សំដៅដល់លេខកូដខ្លី ៣ ឬ ៤ ខ្ទង់ ដែលផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា ជូនទៅក្រសួង ឬស្ថាប័នរដ្ឋដូចជាអគ្គស្នងការនគរបាលជាតិ អគ្គស្នងការសន្តិសុខជាតិ ក្រោមឱវាទក្រសួងមហាផ្ទៃ និង/ឬ អង្គភាព ឬ គ្រឹះស្ថានក្រោមឱវាទក្រសួងសុខាភិបាល ដើម្បីផ្តល់សេវាទូរគមនាគមន៍ដែលត្រូវបានប្រើប្រាស់ក្នុងគ្រាអាសន្ន ដោយសាធារណជន ដោយមិនគិតថ្លៃ។
- **លេខកូដខ្លី** (Short Code Number) សំដៅដល់លេខកូដខ្លី ៣ ឬ ៤ខ្ទង់ ដែលមិនមែនជាលេខកូដខ្លីសម្រាប់សេវាគ្រាអាសន្ន សម្រាប់ផ្តល់សេវាហៅចូល ឬហៅចេញ ដែលមានពីរប្រភេទ រួមមាន៖
    - លេខកូដខ្លី (Operator Short Code) ដែលត្រូវបានផ្តល់ការអនុញ្ញាតជូនដល់ប្រតិបត្តិករទូរស័ព្ទចល័ត អចល័ត មាត់ច្រកទូរគមនាគមន៍អន្តរជាតិ និងសេវាសំឡេងតាមអាយភី (VoIP) សម្រាប់ផ្តល់សេវាទូរគមនាគមន៍ ជូនសាធារណជន
    - លេខកូដខ្លី (Customer Short Code) ដែលបានផ្តល់ជូនបណ្តាក្រសួង ស្ថាប័នរដ្ឋ/ឯកជន អង្គការ និងក្រុមហ៊ុនសម្រាប់ផ្តល់សេវាជូនសាធារណជន ។

## ជំពូកទី២
## ការកំណត់តម្លៃនៃការប្រើប្រាស់លេខទូរគមនាគមន៍

**មាត្រា៤ .-**

ការគិតតម្លៃនៃការប្រើប្រាស់លេខទូរស័ព្ទ **ចល័ត** គឺត្រូវគិតទៅតាមចំនួនក្បាលលេខដែលប្រតិបត្តិករកាន់កាប់។

**ក) ការកំណត់ទម្រង់ និងចំនួនលេខទូរស័ព្ទចល័ត**

១) លេខទូរស័ព្ទចល័ត ៦ (ប្រាំមួយ) ខ្ទង់ (0MN AXX XXX) មានចំនួន ៨០០.០០០ (ប្រាំបីរយពាន់) លេខ។

២) លេខទូរស័ព្ទចល័ត ៧ (ប្រាំពីរ) ខ្ទង់ (0MN AXXX XXX) មានចំនួន ៨.០០០.០០០ (ប្រាំបីលាន) លេខ ។

ដែលក្នុងនោះ រួមមាន៖

- MN ជាលេខកូដសម្គាល់ក្រុមហ៊ុនទូរស័ព្ទចល័ត
- A ជាចំនួនលេខអាចយកចាប់ពីលេខ ២ រហូតដល់លេខ ៩
- X ជាចំនួនលេខអាចយកចាប់ពីលេខ 0 រហូតដល់លេខ ៩។

**<u>ខ) កម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទចល័ត (ទាំងលេខកំពុងដំណើរការ និង លេខពុំទាន់ដំណើរការ) ត្រូវគិតទៅតាមអត្រា (ដោយពុំទាន់គិតអាករលើតម្លៃបន្ថែម និងអាករពិសេស) ដូចតារាងខាងក្រោម៖</u>**

| **ឆ្នាំអនុវត្ត** | **អត្រាកម្រៃនៃការប្រើប្រាស់លេខ (គិតជាដុល្លារអាមេរិក)** | **អនុវត្ត** |
|---|---|---|
| ២០១៧ | ០,០៥ /មួយលេខ/មួយឆ្នាំ | ទាំងលេខដំណើរការ និងលេខពុំទាន់ដំណើរការ។ |
| ២០១៨ | ០,០៥ /មួយលេខ/មួយឆ្នាំ | ទាំងលេខដំណើរការ និងលេខពុំទាន់ដំណើរការ។ |
| ២០១៩ | ០,០៦ /មួយលេខ/មួយឆ្នាំ | ទាំងលេខដំណើរការ និងលេខពុំទាន់ដំណើរការ។ |
| ២០២០ | ០,០៦ /មួយលេខ/មួយឆ្នាំ | ទាំងលេខដំណើរការ និងលេខពុំទាន់ដំណើរការ។ |
| ២០២១ | ០,០៨ /មួយលេខ/មួយឆ្នាំ | ទាំងលេខដំណើរការ និងលេខពុំទាន់ដំណើរការ។ |

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវបង់កម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទចល័តជាប្រចាំខែជូន **ក.ប.ទ.**។ ការគណនាកម្រៃលេខទូរស័ព្ទប្រចាំខែ ត្រូវផ្អែកលើសមាមាត្រនៃអត្រាកម្រៃប្រចាំឆ្នាំ ដូចមានចែងក្នុងតារាងខាងលើនៃមាត្រានេះ។

**មាត្រា៥ .-**

ការគិតកម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទ **អចល័ត** គឺត្រូវគិតទៅតាមចំនួនប្លុកលេខដែលប្រតិបត្តិករកាន់កាប់។

**<u>ក) ការកំណត់ទម្រង់ និងការបែងចែកប្លុកលេខ</u>**

១) ក្នុងមួយប្លុកត្រូវបានកំណត់ចំនួន ១.០០០ (មួយពាន់) លេខ ។

២) លេខទូរស័ព្ទអចល័ត ៦ (ប្រាំមួយ) ខ្ទង់ (0AB NXX XXX) មានចំនួន ៨០០.០០០ (ប្រាំបីរយពាន់) លេខ ស្មើនឹង ៨០០ (ប្រាំបីរយ) ប្លុក/មួយកូដតំបន់ឬខេត្ត (Area Code)។

៣) លេខទូរស័ព្ទអចល័ត ៧ (ប្រាំពីរ) ខ្ទង់ (0AB NXXX XXX) មានចំនួន ៨.០០០.០០០ (ប្រាំបីលាន) លេខ ស្មើនឹង ៨.០០០ (ប្រាំបីពាន់) ប្លុក/មួយកូដតំបន់ឬខេត្ត (Area Code)។

ដែលក្នុងនោះ រួមមាន៖

- AB ជាលេខកូដតំបន់
- N ជាលេខមួយប្រាកដ (លើកលែងលេខ ០ និង លេខ ១) សម្រាប់សម្គាល់ស្ថានីយ៍ទូរស័ព្ទ ឬ Network Operator នីមួយៗ
- X ជាចំនួនលេខអាចយកចាប់ពីលេខ ០ រហូតដល់លេខ ៩។

**ខ) ការគណនាកម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទអចល័ត និងត្រូវគិតទៅតាមអត្រា (ដោយពុំទាន់គិតអាករលើតម្លៃបន្ថែម និង អាករពិសេស) ដូចតារាងខាងក្រោម៖**

| ឆ្នាំអនុវត្ត | អត្រាកម្រៃនៃការប្រើប្រាស់លេខ (គិតជាដុល្លារអាម៉េរិក/មួយឆ្នាំ) | សម្គាល់ |
|---|---|---|
| ២០១៧ | 0,0៥ x ១.000 x ចំនួនប្លុក | - 0,0៥ : ជាកម្រៃនៃការប្រើប្រាស់លេខ<br>- ១.000 : ជាចំនួនលេខក្នុងមួយប្លុក<br>- ចំនួនប្លុក: ជាចំនួនប្លុកលេខដែលប្រតិបត្តិករកាន់កាប់។ |
| ២០១៨ | 0,0៥ x ១.000 x ចំនួនប្លុក | - 0,0៥ : ជាកម្រៃនៃការប្រើប្រាស់លេខ<br>- ១.000 : ជាចំនួនលេខក្នុងមួយប្លុក<br>- ចំនួនប្លុក: ជាចំនួនប្លុកលេខដែលប្រតិបត្តិករកាន់កាប់។ |
| ២០១៩ | 0,0៦ x ១.000 x ចំនួនប្លុក | - 0,0៦ : ជាកម្រៃនៃការប្រើប្រាស់លេខ<br>- ១.000 : ជាចំនួនលេខក្នុងមួយប្លុក<br>- ចំនួនប្លុក: ជាចំនួនប្លុកលេខដែលប្រតិបត្តិករកាន់កាប់។ |
| ២០២០ | 0,0៦ x ១.000 x ចំនួនប្លុក | - 0,0៦ : ជាកម្រៃនៃការប្រើប្រាស់លេខ<br>- ១.000 : ជាចំនួនលេខក្នុងមួយប្លុក<br>- ចំនួនប្លុក: ជាចំនួនប្លុកលេខដែលប្រតិបត្តិករកាន់កាប់។ |
| ២០២១ | 0,0៨ x ១.000 x ចំនួនប្លុក | - 0,0៨ : ជាកម្រៃនៃការប្រើប្រាស់លេខ<br>- ១.000 : ជាចំនួនលេខក្នុងមួយប្លុក<br>- ចំនួនប្លុក: ជាចំនួនប្លុកលេខដែលប្រតិបត្តិករកាន់កាប់។ |

ប្រតិបត្តិករត្រូវបង់កម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទអចល័តជាប្រចាំខែជូន **ក.ប.ទ.**។ ការគណនាកម្រៃលេខទូរស័ព្ទប្រចាំខែ ត្រូវផ្អែកលើសមាមាត្រនៃអត្រាកម្រៃប្រចាំឆ្នាំ ដូចមានចែងក្នុងតារាងខាងលើនៃមាត្រានេះ។

**មាត្រា៦ .-**

កម្រៃនៃការប្រើប្រាស់លេខទូរគមនាគមន៍ផ្សេងៗ (កម្រៃត្រូវបង់ប្រចាំឆ្នាំជូន ន.ទ.ក.)

- ១.000 (មួយពាន់) ដុល្លារអាមេរិកក្នុងមួយកូដ ចំពោះលេខកូដខ្លីសម្រាប់ប្រតិបត្តិករ (Operator Short Code)។

- ១.០០០ (មួយពាន់) ដុល្លារអាមេរិកក្នុងមួយកូដ ចំពោះលេខកូដខ្លីសម្រាប់អតិថិជន (Customer Short Code)។
- ២.០០០ (ពីរពាន់) ដុល្លារអាមេរិកក្នុងមួយកូដ ចំពោះលេខកូដមាត់ច្រកទូរគមនាគមន៍ អន្តរជាតិ (International Telecommunication Gateway Access Code : IDD ឬ VoIP) ។
- ១.០០០ (មួយពាន់) ដុល្លារអាមេរិកក្នុងមួយកូដ ចំពោះលេខកូដ Toll-Free (១៨០០)។
- ១.០០០ (មួយពាន់) ដុល្លារអាម៉េរិកក្នុងមួយកូដ ចំពោះលេខកូដ Premium Rate (១៩០០)។
- ២.០០០ (ពីរពាន់) ដុល្លារអាម៉េរិកក្នុងមួយកូដ ចំពោះលេខកូដបណ្តាញចល័ត (Mobile Network Code - MNC)។
- ២៥០ (ពីររយហាសិប) ដុល្លារអាមេរិកក្នុងមួយកូដ ចំពោះកូដចំណុចស៊ីញ៉ាល់ជាតិ (National Signal Point Code - NSPC)។
- ២.០០០ (ពីរពាន់) ដុល្លារអាម៉េរិកក្នុងមួយកូដ ចំពោះកូដចំណុចស៊ីញ៉ាល់អន្តរជាតិ (International Signaling Point Code - ISPC)។

**មាត្រា៧ .-**

កម្រៃនិយ័តករនឹងត្រូវពិចារណាកែសម្រួលឡើងវិញ នៅពេលណាប្រតិបត្តិករទូរគមនាគមន៍បង្កើតសមាគមទូរគមនាគមន៍ បានសម្រេចរួចរាល់ដោយស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៨ .-**

ចាប់ពីឆ្នាំ២០២២ តទៅ អត្រាកម្រៃនៃការប្រើប្រាស់លេខទូរគមនាគមន៍ និងកម្រៃពាក់ព័ន្ធដទៃ ដូចបានកំណត់នៅក្នុងមាត្រា៤ មាត្រា៥ និង មាត្រា៦ នៃអនុក្រឹត្យនេះនឹងត្រូវពិនិត្យឡើងវិញ អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃការវិវត្តរបស់សង្គម និងសេដ្ឋកិច្ច។

## ជំពូកទី៣
## ការប្រគល់លេខទូរគមនាគមន៍ជូន ន.ទ.ក.

**មាត្រា៩ .-**

ប្រតិបត្តិករទូរស័ព្ទចល័តអាចប្រគល់ក្បាលលេខណាមួយ ឬច្រើន ដែលពុំបានប្រើប្រាស់សោះ (សូម្បីតែមួយលេខ) ជូនមក ន.ទ.ក វិញ។

ប្រតិបត្តិករទូរស័ព្ទអចល័តអាចប្រគល់ក្បាលលេខ ឬ ប្លុកលេខណាមួយ ឬច្រើន ដែលពុំបានប្រើប្រាស់សោះ (សូម្បីតែមួយលេខ) ជូនមក ន.ទ.ក វិញ។

ការប្រគល់ក្បាលលេខ ឬ ប្លុកលេខ ដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រានេះ អាចធ្វើបានតែ ២ (ពីរ) ដងគត់ក្នុងមួយឆ្នាំ គឺនៅក្នុងសប្តាហ៍ទីមួយនៃខែមករា សម្រាប់ឆមាសទី១ និង នៅក្នុងសប្តាហ៍ទីមួយនៃខែកក្កដា សម្រាប់ឆមាសទី២។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា១០ .-**

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ និង/ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ដែលបានទទួលសិទ្ធិកាន់កាប់លេខទូរស័ព្ទ និង លេខទូរគមនាគមន៍ផ្សេងទៀត ពុំព្រមអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១១ .-**

ការកែសម្រួលកម្រៃនៃការប្រើប្រាស់លេខទូរគមនាគមន៍នេះ ត្រូវអនុវត្តចាប់ពីខែកក្កដាឆ្នាំ២០១៧ មក ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និង ន.ទ.ក. ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**អូន ព័ន្ធមុនីរ័ត្ន** | **ត្រាំ អ៊ីវតឹក**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ